ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៤០...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួនពីរ(០២)កន្លែង ជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ រួមមាន៖

ក- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ១៦៦៨ហិកតា (មួយពាន់ប្រាំមួយរយហុកសិបប្រាំបីហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រុមហ៊ុន អេចធីធីអេច អាយលែន អ៊ិនវេសមេន ឯ.ក (HTTH ISLAND INVESTMENT CO., LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ១។

ខ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ«ពាម» លើផ្ទៃដីទំហំ ៤០៩ហិកតា (បួនរយប្រាំបួនហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រុមហ៊ុន CELESTIAL STARS LIMITED COMPANY ធ្វើការវិនិយោគអភិវឌ្ឍន៍គម្រោងសាងសង់ និងដំណើរការមជ្ឈមណ្ឌលកំសាន្ត រួមមាន៖ សណ្ឋាគារ និងរីសត្តអន្តរជាតិ ក្លឹបល្បែងផ្សងសំណាង(កាស៊ីណូ ឆ្នោតឡូតូ...) និងល្បែងក្តាល់កីឡា។ល។ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ២។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៩ ១៣៩ ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ឧបសម្ព័ន្ធ ១ ៖ អនុក្រឹត្យលេខ ២៥០ អនក្រ.បក
ថ្ងៃសុក្រ ៩ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ២០១៨

ផែនទី ទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍និស័យទេសចរណ៍ របស់ក្រុមហ៊ុន អេចធីធីអេច អាយលែន អ៊ិនវេសមេន ឯ.ក (HTTH ISLAND INVESTMENT CO., LTD) នៅលើ«កោះថ្មី» ស្ថិតក្នុងឧទ្យានជាតិព្រះសីហនុ«រាម» ភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ លើផ្ទៃដីធំហាំ ១៦៦៨ ហិកតា



ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ២ ៖ អនុក្រឹត្យលេខ ...១៥០ អនក្រ.បក...
ថ្ងៃ...........ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ថ្ងៃទី...១៥...ខែ...វិច្ឆិកា...ឆ្នាំ២០១៨

ផែនទី ទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍សាងសង់ និងដំណើរការមជ្ឈមណ្ឌលកំសាន្ត រួមមាន៖ សណ្ឋាគារ និងវីឡាអន្តរជាតិ ល្បែងស៊ីសងសំណាង (កាស៊ីណូ ម៉ាស៊ីនស្លត...) និងល្បែងភ្នាល់កីឡា។ល។ របស់ក្រុមហ៊ុន CELESTIAL STARS LIMITED COMPANY នៅលើ«កោះថ្មី» ស្ថិតក្នុងឧទ្យានជាតិព្រះសីហនុ«រាម» ភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ លើផ្ទៃដីទំហំ ៤០៩ ហិកតា



ចំណុចនិយាមកា (CELESTIAL)

No	ID	X	Y
1	A	365107	1157351
2	B	368340	1157351
3	C	368349	1156918
4	D	368387	1156860
5	E	368234	1156076
6	F	367568	1155883
7	G	367021	1155888
8	H	366959	1155716
9	I	366424	1155390

សញ្ញាសម្គាល់

- ចំណុចនិយាមកាព្រំប្រទល់ដី
- ទីតាំងគម្រោង វិនិយោគ
- ព្រំប្រទល់ឧទ្យាន ជាតិព្រះសីហនុ «រាម»



1:20,000

WGS_1984_UTM_Zone_48N

0 500 m